ផ្នែកដែលដើមចោទ X និយាយ

**១.** ខ្ញុំបើករោងចក្រជួសជុលរថយន្ត ។

**២.** មានថ្ងៃមួយ លោក A ដែលជាអ្នករស់នៅជិតខាងខ្ញុំ បានមកប្រាប់ខ្ញុំថា “លោក Y ត្រូវជាសាច់ញាតិខ្ញុំដែលកំពុងបើកហាងលក់រថយន្ត ចង់ខ្ចីប្រាក់ចំនួន១ម៉ឺនដុល្លារ ដើម្បីពង្រីកហាង។ ដោយសារតែនិយាយថានឹងបង់ការប្រាក់ ហេតុនេះហើយ តើអាចឲ្យខ្ចីបានទេ?

**៣.** ដោយសារតែអាជីវកម្មរោងចក្ររបស់ខ្ញុំមានភាពរលូន ហើយខ្ញុំមានប្រាក់សន្សំប្រហែល១ម៉ឺនដុល្លារស្រាប់ ម្យ៉ាងទៀត ដោយសារតែជាការពឹងពាក់របស់អ្នកជិតខាង A ដូចនេះខ្ញុំក៏សម្រេចចិត្តឲ្យប្រាក់ទៅលោក Y ខ្ចី។

**៤.** នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១២ លោក A និង លោក Y បានមកផ្ទះរបស់ខ្ញុំ។ ដូច្នេះហើយ ខ្ញុំបានប្រគល់សាច់ប្រាក់ ចំនួន១ម៉ឺនដុល្លាឲ្យទៅលោក Y និងបានឲ្យលោក Y សរសេរកិច្ចសន្យាខ្ចីប្រាក់ឲ្យមកខ្ញុំ។ពេលកំណត់សងគឺ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១៣ អត្រាការប្រាក់១៥%ក្នុងមួយឆ្នាំ ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្រោយផុតអំឡុងពេលគឺបានសន្យាគ្នាថា ២០% ក្នុងមួយឆ្នាំ។

**៥.** មួយរយៈក្រោយមក ក្នុងអំឡុងខែខែមីនា ឆ្នាំ២០១៣ ម្តងនេះលោក Y បានមកដល់រោងចក្រខ្ញុំតែម្នាក់ឯង។ គាត់បាននិយាយថា“ដោយសារតែ អាជីវកម្មហាងលក់រថយន្ត ដំណើរការល្អលើសពីការរំពឹងទុក ហើយខ្ញុំចង់នាំចូលរថយន្តបន្ថែមដើម្បីលក់។ ដូច្នេះហើយ ខ្ញុំចង់សុំខ្ចីប្រាក់ ៥ពាន់ដុល្លារទៀត ធ្វើជាដើមទុន”។ ខ្ញុំក៏បានលឺពីលោក A ផងដែរថា ហាងរបស់លោក Y មានដំណើរការល្អ ចឹងហើយខ្ញុំបានសម្រេចឲ្យខ្ចីប្រាក់បន្ថែមចំនួន ៥ពាន់ដុល្លារទៀត ហើយនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ ខ្ញុំបានផ្ទេរប្រាក់ចំនួន ៥ពាន់ដុល្លារចូលគណនីធនាគារដែលមានឈ្មោះរបស់លោក Y ។ ពេលនោះ ដោយសារតែវាជាលើកទី២ សម្រាប់ការខ្ចីលុយរបស់ Y ហេតុនេះ ខ្ញុំមិនបានធ្វើកិច្ចសន្យាខ្ចីប្រាក់ និងមិនបាននិយាយឲ្យច្បាស់លាស់អំពីពេលកំណត់សង និង អត្រាការប្រាក់ ជាអាទិ៍ទេ។

**៦.** ប៉ុន្តែ ចាប់តាំងពីពេលខ្ចីប្រាក់ដំបូង រហូតដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៣ ដែលរយៈពេល១ឆ្នាំបានកន្លងផុតហើយក៏ដោយ ក៏លោក Y មិនបានសងប្រាក់មកឲ្យខ្ញុំវិញដែរ។ ហេតុនេះ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ ២០១៣ ខ្ញុំក៏បានទូរស័ព្ទទៅប្រាប់លោក Y ថា ឲ្យប្រញាប់សងប្រាក់ ១ម៉ឺនដុល្លារមកឲ្យខ្ញុំ។ លើសពីនេះ ខ្ញុំក៏បានប្រាប់ផងដែរថា ចង់ឲ្យសងប្រាក់ចំនួន៥ពាន់ដុល្លារដែលបានខ្ចីនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ ត្រឹម៣ខែក្រោយខែគឺនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៤។ ប៉ុន្តែ លោក X និយាយរហូតថា “រង់ចាំបន្តិចទៀតទៅ”។ ក្រោយមក ខ្ញុំបានធ្វើការជូនដំណឹងតាមរយៈទូរស័ព្ទ និង Messenger ជាច្រើនដង ប៉ុន្តែក្នុងអំឡុងខែមេសា ឆ្នាំ២០១៤ Messenger ដែលមានខ្លឹមសារថា “ដោយសារតែអាជីវកម្មហាងលក់រថយន្តដំណើរការមិនល្អ ហេតុនេះ ខ្ញុំចង់ឲ្យពន្យារពេលប្រហែល១ឆ្នាំទៀត”របស់លោក Y បានផ្ញើមកខ្ញុំ។ ប៉ុន្តែ ក្រោយមកខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់ ហើយបានសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេល៣ឆ្នាំ ហេតុនេះ ខ្ញុំមិនបានឆ្លើយតបចំពោះ Messenger នោះទេ ហើយក៏មិនបានធ្វើការដាស់តឿនដែរ។ បច្ចុប្បន្ន ខ្ញុំក៏បានជាសះស្បើយពីជម្ងឺ ហើយគិតថាចង់ទាមទារប្រាក់ដែលឲ្យខ្ចី និងអាត្រាការប្រាក់នោះ។

ផ្នែកដែលចុងចម្លើយ Y និយាយ

**១.** ជាការពិត នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១២ ខ្ញុំបានទៅផ្ទះរបស់លោក X ជាមួយនិងលោក A ហើយបានសរសេរកិច្ចសន្យាខ្ចីប្រាក់ ខ្ញុំគិតថាអាចទទួលប្រាក់នៅកន្លែងនោះ ប៉ុន្តែ X និយាយថា

“រឿងលុយចាំពេលក្រោយ” ហើយខ្ញុំក៏មិនបានទទួលលុយទេ។ លើសពីនេះ នៅពេលល្ងាចថ្ងៃនោះ ខ្ញុំបានទទួលលុយចំនួន១ម៉ឺនដុល្លារពីលោក A ប៉ុន្តែលុយនេះជាលុយដែលខ្ចីពីលោក A មិនមែនជាលុយដែលខ្ចីពីលោក X ។

**២.** ដោយសារ អាជីវកម្មហាងលក់រថយន្តរបស់ខ្ញុំមានដំណើរការល្អ ហេតុនេះ ខ្ញុំបានសងប្រាក់ចំនួន១ម៉ឺនដុល្លារដែលបានខ្ចីពីលោក A  រួមទាំងការប្រាក់១៥%ក្នុងមួយឆ្នាំសរុបចំនួន១៥០០ ដុល្លារ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៣ រួចហើយ។ នៅពេលនោះ លោក A បាននិយាយថា “ ថ្ងៃនេះ ប្រាក់នោះនឹងទៅដល់លោក X” ។

**៣.** លោក X ដូចជាបាននិយាយថា គាត់បានផ្ញើប្រាក់ចំនួន៥ពាន់ដុល្លារនៅខែមីនា ឆ្នាំ២០១៣។ ដោយសារការនិយាយនោះរៀងយូរមកហើយដែរ ហេតុនេះ ខ្ញុំចាំអត់បានទេ ហើយចំពោះការដែលនិយាយថា ខ្ញុំចង់ឲ្យលោក X ខ្ចីប្រាក់បន្ថែម គឺខ្ញុំអត់មានការចងចាំ។